៨

# ការស្តាប់បង្គាប់ព្រះជាម្ចាស់

រៀនចុះចូលចំពោះទិសដៅរបស់ព្រះជាម្ចាស់

**សៀវភៅសំរាប់សិស្ស**

សិក្សាជាក្រុម

**សំរាប់**គ្រិស្តបរិស័ទថ្មី

# មាតិការ


**ជំពូក ១. សេចក្តីស្រលាញ់ និង ការស្តាប់បង្គាប់ ....................................................................................៣**

ក. ហេតុអ្វីជាត្រូវស្តាប់បង្គាប់ព្រះជាម្ចាស់? ......................................................................................៣

ខ. តើខ្ញុំអាចស្តាប់បង្គាប់វិន័យសំខាន់បំផុតរបស់ព្រះជាម្ចាស់ដោយរបៀបណា? ..............................................៤

**ជំពូក ២. អាកប្បកិរិយា និង ការស្តាប់បង្គាប់ .........................................................................................៥**

ក. ពិនិត្យអាកប្បកិរិយាដែលធ្វើអោយមានការងាយស្រួលក្នុងការមិនស្តាប់បង្គាប់ព្រះជាម្ចាស់ .........................៦

ខ. បង្កើតអោយមានអាកប្បកិរិយាស្តាប់បង្គាប់ ...........................................................................................៧

១. អាកប្បកិរិយាគួរអោយគោរព.............................................................................................................៧

២. អាកប្បកិរិយាជាអ្នកបំរើ....................................................................................................................៨

៣. អាកប្បកិរិយាដឹងគុណ........................................................................................................................៨

៤. អាកប្បកិរិយាស្មោះស្ម័គ្រ....................................................................................................................៩

**ជំពូក ៣. តើវិន័យណាមួយដែលត្រូវខ្ញុំស្តាប់បង្គាប់? ........................................................................................១០**

ក. ស្តាប់បង្គាប់វិន័យរបស់ព្រះជាម្ចាស់នៅក្នុងសញ្ញាថ្មី...........................................................................................១០

ខ. ស្តាប់បង្គាប់គោលការណ៍នានាដែលក្រិតវិន័យបានចែង........................................................................................១០

គ. តើព្រះទ័យរបស់ព្រះជាម្ចាស់គឺជាអ្វី? ..............................................................................................................១១

**ជំពូក ៤. លទ្ធផលនៃការស្តាប់បង្គាប់ព្រះជាម្ចាស់ ...................................................................................................១៣**

**ជំពូក ៥ លទ្ធផលនៃការមិនស្តាប់បង្គាប់ព្រះជាម្ចាស់......................................................................................................១៤**

# ជំពូក ទី ១

# សេចក្តីស្រលាញ់ និង ការស្តាប់បង្គាប់

## ក. ហេតុអ្វីបានជាត្រូវស្តាប់បង្គាប់ព្រះជាម្ចាស់?

ការស្តាប់បង្គាប់ និង សេចក្តីស្រលាញ់មានទំនាក់ទំនងជាមួយគ្នាយ៉ាងជិតស្និទ្ធ ។ កិច្ចការទាំងពីរនេះមានឥទ្ធិពលយ៉ាងខ្លាំងជាមួយគ្នាទៅវិញទៅមក ។ ប្រសិនបើអ្នកនឹងស្តាប់បង្គាប់ព្រះជាម្ចាស់ អ្នកត្រូវតែរៀនស្រលាញ់ទ្រង់ ។ មានតែទំនាក់ទំនងខាងក្នុងជាមួយនិងព្រះជាម្ចាស់ ដែលពឹងផ្អែកលើសេចក្តីស្រលាញ់ នឹងជួយអ្នកអោយមានបំណងចិត្ត និង អំណាចដើម្បីស្តាប់បង្គាប់ក្រិតវិន័យរបស់ព្រះជាម្ចាស់ ។ សេចក្តីស្រលាញ់គឺជាមូលដ្ឋានគ្រឹះដ៏រឹងមាំ ដែលនាំទៅរកការបង្កើតអោយមានការស្តាប់បង្គាប់ ។ សេចក្តីស្រលាញ់របស់អ្នកកាន់តែធំយ៉ាងណាចំពោះព្រះជាម្ចាស់ ការស្តាប់បង្គាប់ព្រះជាម្ចាស់ក៏ងាយស្រួលយ៉ាងនោះដែរ ។

### ១. ព្រះជាម្ចាស់គឺជាសេចក្តីស្រលាញ់

លក្ខណៈសម្បត្តិ រឺ ចរិត្តលក្ខណៈមួយក្នុងចំណោមចរិត្តលក្ខណៈសម្បត្តិទាំងអស់របស់ព្រះជាម្ចាស់គឺថា ទ្រង់គឺជាព្រះដែលផ្តល់សេចក្តីស្រលាញ់ ។ មានខព្រះគម្ពីរជាច្រើន ដែលនិយាយអំពីសេចក្តីស្រលាញ់របស់ព្រះជាម្ចាស់ ។ សូមមើលទៅ ២កូរិនថូស ១៣:១១ និង យ៉ូហាន ៣:១៦ ជាដើម ។

### ២. ព្រះជាម្ចាស់ស្រលាញ់អ្នក

យ៉ូហាន ៣:១៦ ប្រាប់យើងថា ព្រះជាម្ចាស់ស្រលាញ់ពិភពលោកនេះ មិនគ្រាន់តែសំរាប់មនុស្សមួយចំនួនឡើយ ។ ទ្រង់ស្រលាញ់អ្នកយ៉ាងជ្រាលជ្រៅបំផុត ។ ជីវិតអំពើបាបកាលពីអតីតកាលរបស់អ្នកមិនអាចបញ្ឈប់ទ្រង់មិនអោយស្រលាញ់អ្នកបានឡើយ ។ អ្នកគឺជាមនុស្សដ៏ពិសេសសំរាប់ទ្រង់ ។

### ៣. ព្រះជាម្ចាស់ប្រាប់អ្នកអោយស្រលាញ់ទ្រង់

ក្រិតវិន័យដ៏សំខាន់ជាគេបំផុតនៅក្នុងព្រះគម្ពីរទាំងមូលគឺថា ត្រូវស្រលាញ់ព្រះជាម្ចាស់អោយពីចិត្ត ពីគំនិត ពីព្រលឹង និង ពីកំលាំងរបស់អ្នក ។ (មើល ម៉ាថាយ ២២:២៧ និង ម៉ាកុស ១២:៣០) តាមពាក្យផ្សេងទៀតនិយាយថា ទ្រង់

បញ្ហាអោយយើងស្រលាញ់ព្រះជាម្ចាស់ជាងអ្វីៗទាំងអស់ដែលយើងមាន ។ យើងទាំងអស់គ្នាត្រូវស្រលាញ់ព្រះជាម្ចាស់លើសជាងរបស់អ្វីៗទាំងអស់ រឺ មនុស្សផ្សេងៗទៀត ។

នៅក្នុង យ៉ូហាន ១៤:១៥ ព្រះយេស៊ូបានមានបន្ទូលថា ប្រសិនបើអ្នកស្រលាញ់ទ្រង់ នោះអ្នកនឹងស្តាប់បង្គាប់វិន័យរបស់ព្រះជាម្ចាស់ ។ ផ្ទុយមកវិញ ប្រសិនបើអ្នកមិនស្តាប់បង្គាប់ព្រះជាម្ចាស់ នេះបង្ហាញថា អ្នកមិនបានស្រលាញ់ព្រះជាម្ចាស់ទេ ។ ប្រសិនបើអ្នកមិនស្រលាញ់ព្រះជាម្ចាស់ទេ នោះអ្នកនឹងពិបាកនៅក្នុងការស្តាប់បង្គាប់វិន័យរបស់ព្រះជាម្ចាស់ណាស់ ។

## ខ. តើខ្ញុំអាចស្តាប់បង្គាប់វិន័យសំខាន់បំផុតរបស់ព្រះជាម្ចាស់ដោយរបៀបណា?

តើអ្នកអាចស្តាប់បង្គាប់វិន័យសំខាន់បំផុតរបស់ព្រះជាម្ចាស់ដោយរបៀបណា? តើអ្នកអាចធ្វើអ្វីដើម្បីបង្ហាញព្រះជាម្ចាស់ថា អ្នកស្រលាញ់ទ្រង់? មានវិធីជាច្រើនសំរាប់អ្នកបង្ហាញព្រះជាម្ចាស់ថា អ្នកស្រលាញ់ទ្រង់ ។ នេះគឺជាវិធី ៤ យ៉ាង :

១. គោរពវិន័យរបស់ព្រះជាម្ចាស់

២. ស្តាប់បង្គាប់គោលការណ៍នានាដែលក្រិតវិន័យបានចែង

៣. ផ្តល់សិទ្ធិផ្ទាល់ខ្លួនរបស់អ្នកដល់ព្រះជាម្ចាស់

៤. ធ្វើអ្វីដែលព្រះជាម្ចាស់ចង់អោយអ្នកធ្វើ

# ជំពូក ទី ២

# អាកប្បកិរិយា និង ការស្តាប់បង្គាប់

យើងបានពិភាក្សាគ្នារួមមកហើយ ពីមូលហេតុដែលយើងគួរតែស្តាប់បង្គាប់ព្រះជាម្ចាស់ ។ យើងឃើញថា ក្រឹតវិន័យដ៏សំខាន់បំផុតរបស់ព្រះជាម្ចាស់ គឺផ្តោតតែទៅលើសេចក្តីស្រលាញ់ ។ ឥឡូវនេះ សូមមើលបន្តិចពីរបៀប ដែលអាកប្បកិរិយារបស់យើងជះឥទ្ធិពលលើការប្រព្រឹត្តរបស់យើង ។

សេចក្តីបង្រៀននេះងាយស្រួលប្រាប់យើងជាទូទៅដល់គ្រប់ទាំងអ្នកដឹកនាំរបស់យើង គឺស្តីពីព្រះជាម្ចាស់ និង អ្នកដឹកនាំរបស់យើងនៅលើផែនដី ។

### ក. ការឆែកមើលអាកប្បកិរិយា ដែលនាំអោយយើងងាយស្រួលមិនស្តាប់បង្គាប់ព្រះជាម្ចាស់

អាកប្បកិរិយាគឺជាចង្កោមនៃការគិត ទស្សនៈ ឬក៏ ជាគំរូនៃការគិត ។

ហេតុផលមួយក្នុងចំណោមហេតុផលជាច្រើន ដែលមនុស្សមានការលំបាកក្នុងការស្តាប់បង្គាប់ព្រះជាម្ចាស់ គឺដោយព្រោះពួកគេមានអាកប្បកិរិយាខុសឆ្គងចំពោះទ្រង់ ។ អ្នកប្រហែលជាសួរថា "តើអាកប្បកិរិយារបស់ខ្ញុំមានទាក់ទងទៅនឹងការមិនស្តាប់បង្គាប់ព្រះជាម្ចាស់យ៉ាងដូចម្តេចទៅ? ពិតណាស់ មានការទាក់ទងជាច្រើន! អ្វីដែលអ្នក*គិត* អំពីព្រះជាម្ចាស់នឹងមានឥទ្ធិពលដ៏ខ្លាំងទៅលើការស្តាប់បង្គាប់យ៉ាងល្អរបស់អ្នកចំពោះទ្រង់ ។

សូមឆែកមើលថាតើ អ្នកមានអាកប្បកិរិយាទាំងនេះនៅចំពោះព្រះជាម្ចាស់ ឬយ៉ាងណា:

_________ អាកប្បកិរិយាដែលចេះតែថ្កោលទោសគេ ( ជាអាកប្បកិរិយារិះគន់គេ)

_________ អាកប្បកិរិយាដែលចេះតែប៉ះបោល

_________ អាកប្បកិរិយាដែលមិនចេះដឹងគុណគេ

_________ អាកប្បកិរិយាដែលខ្ជិលច្រអូស

_________ អាកប្បកិរិយាដែលមានចិត្តគំ

_________ អាកប្បកិរិយារឹងរូស

តើមានមនុស្សបង្ហាញថា ខ្លួនមានចំនុចមួយ រឺ ច្រើននៃអាកប្បកិរិយាទាំងនេះចំពោះព្រះជាម្ចាស់ដោយរបៀបណា? មានវិធីជាច្រើន គឺថា ដោយតាមរយៈអ្វីដែលអ្នកនិយាយ, តាមរយៈអ្វីដែលអ្នកធ្វើ, រឺក៏ ជារបៀបដែលប្រតិកម្ម នៅពេលដែលព្រះជាម្ចាស់ប្រាប់អ្នកអោយធ្វើអ្វីមួយ ។ល ។

អ្នកប្រហែលជាសួរថា "តើខ្ញុំអាចចាកចេញផុតពីអាកប្បកិរិយាទាំងអស់នេះបានដោយរបៀបណា?" ចំលើយគឺពិតជាច្បាស់ណាស់ ។ ជំនួសអាកប្បកិរិយាដែលខុសឆ្គង ដោយអាកប្បកិរិយាដែលស្តាប់បង្គាប់វិញ ។

## ខ. ការបង្កើតអាកប្បកិរិយាដែលចេះស្តាប់បង្គាប់

ផ្នែកមួយដ៏មានសារសំខាន់ក្នុងចំណោមផ្នែកដ៏ទៃផ្សេងៗទៀតនៃការរៀនពីរបៀបស្តាប់បង្គាប់ព្រះជាម្ចាស់ គឺការបង្កើតអាកប្បកិរិយាដែលចេះស្តាប់បង្គាប់ ។ ភីលីព ២:៥ ប្រាប់យើងថា ការមានអាកប្បកិរិយាដូចគ្នានិងព្រះគ្រីស្ទមានដែរ ។ តើអាកប្បកិរិយាប្រភេទណាខ្លះ ដែលព្រះយេស៊ូមានចំពោះអស់អ្នកដែលមានសិទ្ធិអំណាចលើទ្រង់?

### ១. អាកប្បកិរិយាដែលចេះគោរព

#### ក. តើអ្វីជាអាកប្បកិរិយាដែលចេះគោរព

១.) ការគោរពមានន័យថា គោរពដោយរួមបញ្ចូលទាំងសេចក្តីស្រលាញ់ ។ ការគោរពរបស់អ្នករួមបញ្ចូលទាំងសេចក្តីស្រលាញ់របស់សំរាប់ទ្រង់ ។

២.) ការកោតសរសើរ — អ្នកកោតសរសើរព្រះជាម្ចាស់ ។ អ្នកសំលឹងទៅទ្រង់ដោយការគោរព ហើយនោះមានន័យថា អ្នកលើកកិត្តិយសទ្រង់ ។

#### ខ. តើអ្នកបង្កើតអាកប្បកិរិយាដែលចេះគោរពបានដោយរបៀបណា?

១) ត្រូវស្វែងយល់ថា ព្រះជាម្ចាស់កំពុងធ្វើការនៅក្នុងជីវិតរបស់អ្នកតាមរយៈអ្នកដឹកនាំរបស់អ្នក ។

២) ចូរចងចាំថា ព្រះជាម្ចាស់កំពុងប្រើអ្នកដឹកនាំរបស់អ្នកធ្វើអោយអ្នកក្លាយខ្លួនទៅជាមនុស្សដែលព្រះជាម្ចាស់ចង់អោយអ្នកក្លាយទៅជា ។ សុភាសិត ២១:១

៣) សូមសំលឹងមើលអ្នកដឹកនាំរបស់អ្នកថា ប្រៀបបីដូចជា "ព្រះហស្តរបស់ទ្រង់" ដែលដឹកនាំអ្នក និង កែតំរង់អ្នក ។

### ២. អាកប្បកិរិយាជាអ្នកបំរើ

#### ក. តើអ្វីទៅជាអាកប្បកិរិយាជាអ្នកបំរើ?

១) ត្រូវស្វែងយល់ថា ខ្លួនខ្ញុំមិនមែនជាចៅហ្វាយលើខ្លួនឯងឡើយ ។

២) ខ្ញុំទទួលស្គាល់ថា ខ្ញុំពិតជាកំពុងបំរើព្រះជាម្ចាស់ នៅពេលខ្ញុំកំពុងធ្វើអោយអ្នកដឹកនាំរបស់ខ្ញុំ ។ កូឡូស ៣:២៣

៣)	ការនេះមានន័យថា ខ្ញុំកំពុងធ្វើការងារសំរាប់ព្រះជាម្ចាស់នៅក្នុងគ្រប់កិច្ចការដែលខ្ញុំធ្វើ ហើយជាពិសេសនៅក្នុងការស្តាប់បង្គាប់ព្រះជាម្ចាស់ និង អ្នកដឹកនាំរបស់ខ្ញុំ ។

**ខ.	តើខ្ញុំអាចបង្កើតអាកប្បកិរិយាជាអ្នកបំរើបានដោយរបៀបណា?**

១)	ខ្ញុំចុះចូលចំពោះព្រះជាម្ចាស់ និង អ្នកដឹកនាំរបស់ខ្ញុំដោយចិត្តត្រឹមត្រូវ ហើយស្តាប់បង្គាប់ដល់ពួកគេ ។ ១ពេត្រុស ២:១៨

២)	ខ្ញុំដាក់ខ្លួនរបស់នៅក្រោមការការពាររបស់ព្រះជាម្ចាស់

៣)	ខ្ញុំស្វែងរកនូវវិធីផ្សេងៗ ដើម្បីជួយធ្វើអោយនរណាម្នាក់ទៀតមានជ័យជំនះ ហើយជាពិសេសគឺ អ្នកដឹកនាំរបស់ខ្ញុំ ។ ខ្ញុំមានចិត្តត្រេកអរចំពោះការនេះ ហើយក៏ រកឃើញនូវសុភមង្គលដ៏ពិតប្រាកដក្នុងការធ្វើកិច្ចការនេះ ។

៤)	កុំព្យាយាមធ្វើកិច្ចការរបស់ព្រះជាម្ចាស់ឡើយ ។ កុំព្យាយាមយកការទទួលខុសត្រូវរបស់ទ្រង់ឡើយ ។

**៣.	អាកប្បកិរិយាដែលចេះដឹងគុណ (រឺ អាកប្បកិរិយាចេះអរគុណ)**

**ក.	តើអ្វីទៅជាអាកប្បកិរិយាដែលចេះដឹងគុណ?**

១)	ត្រូវចេះអរព្រះគុណសំរាបការដែលព្រះជាម្ចាស់ធ្វើជាអ្នកដឹកនាំរបស់ខ្ញុំ ។

២)	តែងតែមានសេចក្តីអំណរជាប្រចាំ ហើយកោតសរសើរនូវអ្វីដែលព្រះជាម្ចាស់កំពុងធ្វើដើម្បីធ្វើអោយអ្នកក្លាយទៅជាមនុស្សដែលទ្រង់ចង់អោយអ្នកក្លាយទៅជា ។

**ខ.	តើខ្ញុំអាចបង្កើតអាកប្បកិរិយាដែលចេះដឹងគុណបានដោយរបៀបណាខ្លះ?**

១)	រៀនចេះមានចិត្តអំណរកាលដែលព្រះជាម្ចាស់ធ្វើជាចៅហ្វាយរបស់អ្នក ។ អរគុណព្រះជាម្ចាស់ជារៀងរាល់ថ្ងៃ ដែលថាអ្នកគឺជាកូនរបស់ទ្រង់ ។ ១ថេស្សាឡូនិក ៥:១៨

២)	បង្ហាញការកោតសរសើរចាប្រចាំទៅព្រះជាម្ចាស់ជារៀងរាល់ថ្ងៃ ។ ត្រូវអរគុណព្រះជាម្ចាស់នៅពេលណាក៏ដោយ អោយតែទ្រង់ប្រើមនុស្សផ្សេងទៀត ដើម្បីផ្តល់ប្រឹក្សាអ្នក រឺ ក៏កែតំរង់អ្នក ។

៣)	ថ្វាយគ្រប់ទាំងសេចក្តីរំពឹងគិតទុករបស់អ្នកទៅព្រះជាម្ចាស់ ។ សូមធ្វើជាតារាងមួយដែលរៀបរាប់ពីអ្វីៗដែលអ្នករំពឹងគិតថា ចង់អោយទ្រង់ធ្វើសំរាប់អ្នក ។ បន្ទាប់មកអធិស្ឋាន ហើយថ្វាយគ្រប់ទាំងការរំពឹងគិតទុកទាំងអស់នេះទៅព្រះជាម្ចាស់ ។

## ៤. អាកប្បកិរិយាស្មៀមស្ងាត់

### ក. តើអ្វីទៅជាអាកប្បកិរិយាស្មៀមស្ងាត់?

១) វាជាការដ៏សាមញ្ញណាស់ - រៀនពីរបៀបដែលមានភាពស្ងៀមស្ងាត់ ។ សូមរៀនពីរបៀបស្ងាត់ចំពោះអ្វីដែលអ្នកនិយាយ គឺថា មានវិធីពីរ (១) របៀបដែលអ្នកនិយាយ និង (២) របៀបដែលអ្នកនិយាយវាលឺប៉ុណ្ណា ។

២) ការរៀនពីការស្ងៀមស្ងាត់កើតនៅខាងក្នុងចិត្ត និង ខាងក្រៅផងដែរ ។

៣) ការរៀនអោយចេះមានសន្តិភាពជាមួយព្រះជាម្ចាស់

**១ពេត្រុស ៣:៤**

**តែត្រូវតុបតែងខាងក្នុងជំរៅចិត្តរបស់បងប្អូនដោយគ្រឿងលំអ ដែលមិនចេះរលាយ ហើយមានតំលៃដ៏លើសលុប នៅចំពោះព្រះភ័ក្ត្រព្រះជាម្ចាស់នោះវិញគឺ មានចិត្តស្លូតបូត ស្រគត់ស្រគំ ។**

ខគម្ពីរនេះត្រូវបានសរសេរឡើងទៅកាន់ប្រពន្ធៗ អំពីអាកប្បកិរិយារបស់ពួកនាងដែលប្រព្រឹត្តចំពោះស្វាមីរបស់ពួកគេ ។ ទោះជាយ៉ាងណាក្តី គោលការណ៏នោះគឺល្អប្រពៃណាស់សំរាប់គ្រប់មនុស្សរាល់រូប — ការបង្កើតអាកប្បកិរិយាស្ងៀមស្ងាត់ ។ ព្រះជាម្ចាស់ពិចារណាកិច្ចការនេះថា ជាអ្វីមួយដ៏មានតំលៃណាស់ ។

### ខ. តើខ្ញុំអាចបង្កើតអាកប្បកិរិយាស្មៀមស្ងាត់បានដោយរបៀបណាខ្លះ?

១) រៀនស្តាប់បង្គាប់ព្រះជាម្ចាស់ ដោយមិនចាំបាច់ទាមទារចង់ដឹងពីគ្រប់ទាំងមូលហេតុរបស់ទ្រង់ ។ ត្រូវមានបំណងចិត្តស្តាប់បង្គាប់ ដោយព្រោះព្រះបន្ទូលប្រាប់អ្នកអោយធ្វើវា ។

២) ដាក់សេចក្តីទុកចិត្តរបស់អ្នកនៅក្នុងព្រះជាម្ចាស់ ដែលថាទ្រង់នឹងមានលទ្ធភាពធ្វើការតាមរយៈអ្នកដឹកនាំរបស់អ្នក ដើម្បីធ្វើកិច្ចការនៅក្នុងជីវិតរបស់អ្នកដែលទ្រង់សព្វព្រះហឫទ័យចង់ធ្វើ ។ ទុកចិត្តព្រះជាម្ចាស់លើការការធ្វើកិច្ចការនេះ ទោះបើអ្នកដឹកនាំរបស់អ្នកបានមានកំហុស ហើយបានធ្វើខុសក៏ដោយ ។ សូមមើល ១ពេត្រុស ២:២៣

៣) កុំឈ្លូសប្រកែកនិងព្រះជាម្ចាស់ឡើយ

៤) កុំព្យាយាមទាមទាររកការពន្យល់ហេតុផលចំពោះអ្វី ដែលអ្នកធ្វើកិច្ចការណាមួយ មុនពេលអ្នកនឹងស្តាប់បង្គាប់នោះឡើយ ។

នៅពេលដែលអ្នកពិនិត្យមើលនៅក្នុងជីវិតរបស់ព្រះយេស៊ូ អ្នកនឹងរកឃើញថា ទ្រង់បានបង្កើតអាកប្បកិរិយាស្តាប់បង្គាប់ទាំងនេះនៅក្នុងជីវិតរបស់ទ្រង់ ។ ទ្រង់បានបង្ហាញអាកប្បកិរិយាទាំងនេះនៅក្នុងទំនាក់ទំនងរបស់ទ្រង់ជាមួយព្រះជាម្ចាស់ និង អ្នកដឹកនាំរបស់ដែលនៅលើផែននេះ ។

នៅពេលដែលអ្នកខិតខំបង្កើតនូវអាកប្បកិរិយាស្តាប់បង្គាប់ទាំងបួននេះ នោះអ្នកនឹងស្វែងរកឃើញវាយ៉ាងងាយស្រួលក្នុងការស្តាប់បង្គាប់ព្រះជាម្ចាស់ ។

# ជំពូកទី ៣
# តើក្រិត្យវិន័យណាមួយ ដែលខ្ញុំស្តាប់បង្គាប់?

## ក. ស្តាប់បង្គាប់ក្រិត្យវិន័យរបស់ព្រះជាម្ចាស់នៅក្នុងគម្ពីរសញ្ញាថ្មី

១យ៉ូហាន ៥:៣ នៅក្នុងព្រះគម្ពីរចែងថា "ការស្រលាញ់ព្រះជាម្ចាស់មានន័យថា ស្តាប់បង្គាប់ព្រះបន្ទូលរបស់ទ្រង់ ហើយព្រះបន្ទូលរបស់ទ្រង់មិនពិបាកស្តាប់បង្គាប់ឡើយ ។" នៅក្នុងព្រះគម្ពីរសញ្ញាថ្មី ព្រះជាម្ចាស់បានប្រទានក្រិត្យវិន័យជាច្រើនដល់យើង ដែលពន្យល់នូវអ្វីដែលព្រះជាម្ចាស់ចង់អោយយើងធ្វើ ហើយអ្វីដែលយើងមិនត្រូវធ្វើ ។ សូមមើល ម៉ាថាយ ៥, ៦, និង ៧, ម៉ាកុស ១២:៣០-៣១, យ៉ូហាន ១៣:៣៤, រ៉ូម ១៣:១-២ និង អេភេសូ ៦:១-៣ ។

ការស្តាប់បង្គាប់ក្រិត្យវិន័យរបស់ព្រះជាម្ចាស់គឺជាវិធីមួយពីការបង្ហាញព្រះជាម្ចាស់ថា អ្នកស្រលាញ់ទ្រង់ ។

## ខ. ស្តាប់បង្គាប់គោលការណ៍នានាដែលក្រិត្យវិន័យបានចែង

ក្រិត្យវិន័យនៅក្នុងព្រះគម្ពីរសញ្ញាចាស់ត្រូវបានសរសេរឡើងទៅកាន់ប្រជាជាតិអ៊ីស្រាអែល (សាសន៍យូដា) ។ ច្រើនជាង៦០០ក្រិត្យវិន័យត្រូវបានប្រទានអោយដល់ប្រជាជាតិអ៊ីស្រាអែល ដើម្បីណែនាំពួកគេនៅក្នុងការបង្កើតបរិយាកាសរបស់ពួកគេ ច្បាប់ទំលាប់ទាក់ទងទៅនិងសុខភាព និង តំណម រឺក៏ គោលលទ្ធិនានា ។

ព្រះយេស៊ូបានយាងមកដើម្បីបំពេញក្រិត្យវិន័យនៅក្នុងគម្ពីរសញ្ញាចាស់ ហើយណែនាំពីសម្ពន្ធ័មេត្រីថ្មីមួយជាមួយនិងគ្រីស្ទបរិសទ័គ្រប់រូប ។ យើងទាំងអស់គ្នាមិនមានកាព្វកិច្ចក្នុងស្តាប់បង្គាប់តាមក្រិត្យវិន័យគម្ពីរសញ្ញាចាស់ទៀតទេ ។ បើទោះជាយ៉ាងណាក៏ដោយ គោលការណ៍នានាដែលក្រិត្យវិន័យសញ្ញាចាស់បានចែងអាចបង្រៀនយើងពីមេរៀនមួយដែលថា យើងអាចយកមកអនុវត្តទៅនិងស្ថានភាពផ្សេងៗគ្នា ដែលយើងជួបប្រទះនៅក្នុងជីវិតប្រចាំថ្ងៃរបស់យើង ។

ព្រះគម្ពីរមិនបានផ្តល់អោយយើងនូវក្រិត្យវិន័យជាក់លាក់ណាមួយ ដែលប្រាប់អ្នកយ៉ាងច្បាស់លាស់នូវអ្វីដែលធ្វើនៅក្នុងគ្រប់ស្ថានភាពដែលជួបប្រទះនោះទេ ។ ឧទាហរណ៍ ព្រះគម្ពីរមិនមានក្រិត្យដែលនិយាយថា "សូមកុំបើកបរឡានរបស់លើសល្បឿនដែលបានកំណត់ ។" រឺក៏ "សូមកុំប្រើថ្នាំហេរ៉ូអ៊ីនឡើយ" ប៉ុន្តែព្រះគម្ពីរពិតជាបានផ្តល់អោយយើងនូវគោលការណ៍នានា ដែលយើងអាចយកមកអនុវត្តនៅក្នុងគ្រប់ស្ថានភាពទាំងអស់នេះ ។

ព្រះគម្ពីរពិតជាបានចែងនៅក្នុង រ៉ូម ១៣:១-២ ថា អ្នក "ត្រូវតែស្តាប់បង្គាប់អ្នកដឹកនាំនៅក្នុងទឹកដីនេះ ។" អ្នកដឹកនាំប្រទេសជាតិយើង រឺ អ្នកដឹកនាំរដ្ឋយើង ដែលពួកគេបានបង្កើតនូវច្បាប់ទំលាប់ស្តីពីការកំណត់ល្បឿនបើកបរ ។ ដូច្នេះហើយ

យើងមានការទទួលខុសត្រូវ ដើម្បីស្តាប់បង្គាប់ច្បាប់ការកំណត់ល្បឿនបើកបរទាំងនេះ ពីព្រោះថា គោលការណ៍ចេញពីច្បាប់នេះមានចែងនៅក្នុង រ៉ូម ១៣:១-២ ។

ព្រះគម្ពីរចែងនៅក្នុង ១កូរិនថូស ៦:១៩-២០ ថា រូបកាយរបស់អ្នក "គឺជាព្រះវិហាររបស់ព្រះជាម្ចាស់ ដែលព្រះវិញ្ញាណដ៏វិសុទ្ធគង់នៅ ..... ដូច្នេះសូមបងប្អូនលើកកិត្តិយសព្រះជាម្ចាស់ជាមួយនិងរូបកាយរបស់អ្នក ......." ប្រសិនបើអ្នកនឹងស្តាប់បង្គាប់គោលការណ៍នេះរបស់ព្រះជាម្ចាស់ នោះមានន័យថា អ្នកមិនត្រូវបំផ្លាញរូបកាយរបស់អ្នកដោយការប្រើប្រាស់ថ្នាំញៀនឡើយ ។ មួយវិញទៀតការប្រើប្រាស់ថ្នាំញៀនគឺជាការប្រព្រឹត្តខុសនឹងច្បាប់របស់ប្រទេសនោះ ។

វាជាការដ៏មានសារសំខាន់ណាស់សំរាប់អ្នក ក្នុងការសិក្សាព្រះគម្ពីរដើម្បីស្វែងរកគោលការណ៍នានារបស់ព្រះជាម្ចាស់សំរាប់ការរស់នៅរបស់ជារៀងរាល់ថ្ងៃ ។ នៅពេលដែលអ្នកចាប់ផ្តើមដាក់សិរិយាបថរបស់អ្នកតាមគំរូនៃគោលការណ៍នានានៅក្នុងព្រះគម្ពីរ នោះអ្នកនឹងមានលទ្ធភាពបង្ហាញទ្រង់ថា អ្នកស្រលាញ់ទ្រង់ ។ សូមមើល ម៉ាថាយ ២៣:២៣ ។

ព្រះវិញ្ញាណដ៏វិសុទ្ធនឹងជួយអ្នកអោយស្វែងយល់នូវគោលការណ៍នានា ដែលក្រិត្យវិន័យរបស់ព្រះជាម្ចាស់បានចែង ។ ទ្រង់ក៏នឹងជួយដល់អ្នកអោយមើលឃើញផងដែរ ពីរបៀបដែលគោលការណ៍ទាំងនេះអាចយកមកអនុវត្តក្នុងគ្រប់ស្ថានភាពដែលអ្នកជួបប្រទះ ។

## គ. តើអ្វីទៅជាបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់?

ខ្ញុំអាចបង្ហាញព្រះជាម្ចាស់ថា ខ្ញុំស្រលាញ់ទ្រង់ដោយការស្តាប់បង្គាប់ក្រិត្យវិន័យរបស់ទ្រង់ ហើយស្តាប់បង្គាប់គោលការណ៍នានាដែលក្រិត្យវិន័យទាំងនោះបានចែង ។ ខ្ញុំអាចបង្ហាញព្រះជាម្ចាស់ថា ខ្ញុំស្រលាញ់ទ្រង់ដោយការផ្តល់សិទ្ធិផ្ទាល់ខ្លួនរបស់ខ្ញុំទៅទ្រង់ ។ ហើយខ្ញុំអាចបង្ហាញព្រះជាម្ចាស់ថា ខ្ញុំស្រលាញ់ទ្រង់ដោយការធ្វើតាមអ្វី ដែលទ្រង់ចង់អោយខ្ញុំធ្វើ ។ ជាច្រើនលើកច្រើនដង ការទាំងនេះគឺសំដៅទៅលើ "ការធ្វើទៅតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់" អ្វីដែលឃ្លានេះចង់មានន័យគឺថា — ធ្វើអ្វីដែលព្រះជាម្ចាស់ចង់អោយខ្ញុំធ្វើ នៅពេលដែលទ្រង់បើកសំដែងយ៉ាងច្បាស់ដល់ខ្ញុំ ។

យើងនឹងចំណាយពេលបន្តិច ដើម្បីពិចារណាទៅលើកិច្ចការផ្សេងៗ ដែលព្រះជាម្ចាស់ចង់អោយអ្នកចាប់ផ្តើមធ្វើនៅពេលវេលានេះ — គឺមានន័ថា នៅថ្ងៃនេះ!

១. ក្លាយខ្លួនជាគ្រីស្ទបរិសទ័

រ៉ូម ១០:៩, ២ពេត្រុស ៣:៩

២. ឈប់ប្រព្រឹត្តអំពើបាបតទៅទៀត

១ពេត្រុស ២:១១, ១ថេស្សាឡូនិក ៥:២២

៣. ចាប់ផ្តើមធ្វើកិច្ចការណា ដែលត្រឹមត្រូវិញម្តង

រ៉ូម ១២:១,២,៩

៤. ចំណាយពេលវេលាធ្វើការងារជាគ្រីស្ទបរិសទ័

ម៉ាថាយ ៦:១៩-២១

៥. នឹងជួបបញ្ហា និង ការល្បួងល

យ៉ាកុប ១:២-៤

៦. រៀនឆ្លើយតបតាមរបៀបព្រះជាម្ចាស់

រ៉ូម ៨:២៩

៧. រៀនស្វែងយល់ពីតំរូវការរបស់អ្នកដ៏ទៃ

១កូរិនថូស ១៣:៤-៨

៨. ចែកចាយជាមួយអ្នកផ្សេងទៀតនូវអ្វីដែលព្រះគ្រីស្ទបានធ្វើសំរាប់អ្នក

១ពេត្រុស ៣:១៥

អ្នកអាចចាប់ផ្តើមធ្វើកិច្ចការទាំងអស់នេះនៅពេលឥឡូវបាន ។ ការទាំងអស់នេះហើយ ដែលព្រះជាម្ចាស់ចង់អោយអ្នកធ្វើ ។

# ជំពូកទី ៤

# លទ្ធផលកើតចេញពីការស្តាប់បង្គាប់ព្រះជាម្ចាស់

តើមានអ្វីកើតឡើង នៅពេលខ្ញុំស្តាប់បង្គាប់ក្រិត្យវិន័យរបស់ព្រះជាម្ចាស់? មានវិធីមួយនៃការសំលឹងមើលទៅលើលទ្ធផលនៃការស្តាប់បង្គាប់ទាំងនោះ គឺដោយគ្រាន់តែឆ្លើយទៅនិងសំណួរខាងក្រោមនេះ :

តើការស្តាប់បង្គាប់ចំពោះព្រះជាម្ចាស់ជះឥទ្ធិពលដល់ទំនាក់ទំនងរបស់ខ្ញុំជាមួយនិងមនុស្សទាំងនេះដោយរបៀបណា?

១. ព្រះជាម្ចាស់
២. ខ្លួនខ្ញុំ
៣. ឪពុកម្តាយ និង ក្រុមគ្រួសាររបស់ខ្ញុំ
៤. កូនចៅរបស់ខ្ញុំ
៥. អស់អ្នកដែលខ្ញុំធ្វើការជាមួយ
៦. មនុស្សផ្សេងទៀត

ទាំងនេះជាខគម្ពីរមួយចំនួនដែលនិយាយអំពីលទ្ធផល ដែលកើតចេញពីការស្តាប់បង្គាប់ព្រះជាម្ចាស់ ។

១. សេរីភាព ១៩:៣-៦
២. ទុតិយកថា ១១:២៦-២៨
៣. យ៉ូប ៣៦:១១
៤. សុភាសិត ២:២១
៥. យេរេមី ៧:២៣
៦. ម៉ាឡាគី ៣:៧-១២
៧. យ៉ូហាន ១៤:១៥-១៦
៨. យ៉ូហាន ១៤:២១,២៣
៩. យ៉ូហាន ១៥:១០,១១
១០. រ៉ូម ៥:១៨-១៩
១១. រ៉ូម ៦:១៦
១២. រ៉ូម ៦:២៣
១៣. រ៉ូម ១៣:១-៦
១៤. អេភេសូ ៦:១-៣
១៥. ហេព្រើ ៥:៨-៩
១៦. ១ពេត្រុស ២:១៣-១៧

# ជំពូកទី៥
# លទ្ធផលនៃការមិនស្តាប់បង្គាប់ព្រះជាម្ចាស់

តើមានអ្វីកើតឡើង នៅពេលដែលខ្ញុំមិនស្តាប់បង្គាប់? មារសាតាំងចង់អោយអ្នកជឿថា គ្មានអ្វីណាមួយដែលអាក្រក់នឹងកើតឡើងចំពោះអ្នក រឺក៏ នរណាម្នាក់ផ្សេងទៀត ប្រសិនបើអ្នកមិនស្តាប់បង្គាប់ព្រះជាម្ចាស់ និង ក្រិត្យវិន័យរបស់ទ្រង់ ។ ប៉ុន្តែនោះមិនមែនជាការពិតទេ ។ ព្រះគម្ពីរបានបង្រៀនយ៉ាងច្បាស់ថា វាជាការខុសឆ្គងចំពោះការដែលមិនស្តាប់បង្គាប់ព្រះជាម្ចាស់ ។

ព្រះគម្ពីរប្រើពាក្យសាមញ្ញមួយ ដែលពិពណ៌នាអំពីគ្រប់ទាំងការមិនស្តាប់បង្គាប់ នោះគឺ បាប ។ ព្រះជាម្ចាស់សន្យាថា គ្រប់ទាំងអំពើនឹងត្រូវបានកាត់ទោស ។ ការកាត់ទោសមិនតែងតែមកភ្លាមៗទេ ប៉ុន្តែនឹងពិតជាមកដល់ថ្ងៃណាមួយ ។

យើងអាចសំលឹងមើលលើលទ្ធផលនៃការមិនស្តាប់បង្គាប់ចំពោះព្រះជាម្ចាស់ ដោយការឆ្លើយទៅនឹងសំនួរខាងក្រោមទាំងនេះ :

តើការមិនស្តាប់បង្គាប់ចំពោះព្រះជាម្ចាស់ជះឥទ្ធិពលដល់ទំនាក់ទំនងរបស់ខ្ញុំ ទៅនិងមនុស្សទាំងនេះដោយរបៀបណា?

១. ព្រះជាម្ចាស់
២. ខ្លួនខ្ញុំ
៣. ឪពុកម្តាយ និង ក្រុមគ្រួសាររបស់ខ្ញុំ
៤. កូនចៅរបស់ខ្ញុំ ( ទាំងបច្ចុប្បន្ន និង ទៅអនាគត
៥. មិត្តភក្ត្ររបស់ខ្ញុំ
៦. មនុស្សផ្សេងទៀត

ព្រះគម្ពីរក៏មានទៅដោយឧទាហរណ៍ដ៏គួរសោកសង្រេងស្តីពីលទ្ធផលនៃការមិនស្តាប់បង្គាប់ផងដែរ ។ ទាំងនេះគឺជាខគម្ពីរមួយចំនួនស្តីពីលទ្ធផលនៃការមិនស្តាប់បង្គាប់ ។

១. ទុតិយកថា ១១:២៦-២៨
២. ១សាំមូលអែល ១៣ និង ១៤, ២សាំមូលអែល ១១ និង ១២
៣. យ៉ូប ៣៦:១២
៤. សុភាសិត ២:២២, ៥:២២-២៣, ៦:២៩, ១៣:១៣, ១៥:៩-១០
៥. យេរេមី ១២:១៧
៦. ម៉ាឡាគី ៣:៧-១២
៧. រ៉ូម ៥:១៨-១៩, ៦:១៦, ៦:២៣, ១៣:១-៦
៨. ១ពេត្រុស ២:១៣-១៧